**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៣៤ **អយក.សណន**

# សេចក្តីណែនាំ
# ស្តីពី
# ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្ររៀនពូកែ និងសិស្សពូកែ លើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យានៅមធ្យមសិក្សាទុតិយភូមិ

តាមការសិក្សាបានរកឃើញថានៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើននិស្សិតដែលបានបញ្ចប់ការសិក្សាលើមុខវិជ្ជាជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ( វបវគ ) មានអត្រាមានការងារធ្វើខ្ពស់ ទទួលបានប្រាក់បៀវត្សល្អប្រសើរ និងមានលទ្ធភាពរកការងារធ្វើបានឆាប់រហ័ស។

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើការពង្រឹង និងពង្រីកការអប់រំលើជំនាញទាំងបួន ឆ្លើយតបនឹងទីផ្សារការងារ និងសំដៅអភិវឌ្ឍសេដ្ឋកិច្ចជាតិដើម្បីធ្វើឱ្យសម្រេចបានចក្ខុវិស័យ ២០៣០ និង ២០៥០ របស់ខ្លួនដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មនៅកម្ពុជា។

ជាការគាំទ្រគោលនយោបាយខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និងបង្កើតកម្មវិធីនានា ដើម្បីលើកទឹកចិត្តសិស្សនៅគ្រប់កម្រិតជាពិសេស មធ្យមសិក្សាទុតិយភូមិឱ្យបានចូលសិក្សាប្រកបដោយគុណភាព សិក្សាលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ដោយផ្តោតលើវិធានការដោះស្រាយបញ្ហាក្នុងជីវិតរស់នៅជាក់ស្តែង និងមុខរបរដែលជាមធ្យោបាយជួយសម្រួល និងកែលម្អជីវិត និងការរស់នៅប្រចាំថ្ងៃឱ្យមានប្រាក់ចំណូលខ្ពស់។

គម្រោងអភិវឌ្ឍន៍វិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិ នឹងត្រូវអនុវត្ត រយៈពេល ៥ឆ្នាំ គឺចាប់ផ្តើមពីឆ្នាំ ២០១៧ ដល់ ឆ្នាំ២០២១ ក្រោមកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍអាស៊ី ក្នុងនោះមាន៖

កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្ររៀនពូកែ និងសិស្សពូកែមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យានៅមធ្យមសិក្សាទុតិយភូមិនៃវិទ្យាល័យគោលដៅរបស់គម្រោងទាំងនៅតំបន់ជួបការលំបាក ទាំងនៅតំបន់ធម្មតា។ កម្មវិធីនេះនឹងផ្តល់ជូនដល់សិស្សថ្នាក់ទី ១១ និងទី ១២ ដែលមានលក្ខណៈសម្បត្តិសមស្របទៅនឹងលក្ខខណ្ឌ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

កំណត់សម្រាប់ការជ្រើសរើស និងតាមឯកសារណែនាំរបស់គម្រោង។

ដើម្បីឱ្យដំណើរការកម្មវិធីអាហារូបករណ៍នេះប្រព្រឹត្តទៅប្រកបដោយលទ្ធផលល្អប្រសើរ ក្រសួងអប់រំ យុវជន និងកីឡា សូមណែនាំដូចខាងក្រោម៖

**ក. គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់រាជធានី ខេត្ត (គ.គ.អ.ខ/PSMC)**

គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់រាជធានី ខេត្តត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលដល់ការអនុវត្តកម្មវិធីអាហារូបករណ៍ ដែលមានសមាសភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

១. សមាសភាព

| | |
|---|---|
| 1. ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា | ប្រធាន |
| 2. ប្រធាន ឬអនុប្រធានការិយាល័យមធ្យមសិក្សា | អនុប្រធាន |
| 3. ប្រធាន ឬអនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| 4. មន្ត្រីនៅការិយាល័យមធ្យមសិក្សា | សមាជិក |

២.ភារកិច្ច និងការទទួលខុសត្រូវ

- គ្រប់គ្រងរដ្ឋបាលលើការងារផ្តល់អាហារូបករណ៍ និងអនុវត្តគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគម្រោងដើម្បីធានាដល់ដំណើរការអនុវត្តប្រកបដោយភាពរលូន មានការចូលរួម និងភាពជាម្ចាស់
- ណែនាំបង្កើតគណៈកម្មការអាហារូបករណ៍ថ្នាក់មូលដ្ឋាន ពីដំណើរការនៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្ររៀនពូកែ និងសិស្សពូកែមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា
- ផ្តល់ការណែនាំពីវិធីសាស្ត្រ បច្ចេកទេស និងដំណើរការសម្រាប់ការអនុវត្តសកម្មភាពអប់រំមើលការខុសត្រូវ និងតាមដានសកម្មភាពនៃការផ្តល់អាហារូបករណ៍ដល់សិស្ស
- ផ្តល់វគ្គបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់គ.គ.អ.ម. និងផ្សព្វផ្សាយពីគោលបំណង ទិសដៅ និងគោលការណ៍ ព្រមទាំងនីតិវិធីនានានៃការគ្រប់គ្រង និងអនុវត្តការផ្តល់អាហារូបករណ៍ ដល់សិស្សដោយធានានូវការចូលរួមរបស់សហគមន៍ ដូចជាការជ្រើសរើសសិស្ស ការតាមដានវត្តមាន និងការសិក្សារបស់សិស្សជាដើម
- ចុះត្រួតពិនិត្យលើការជ្រើសរើសសិស្សអាហារូបករណ៍នៅតាមសាលាគោលដៅ
- រៀបចំ និងអនុម័តយល់ព្រមលើបញ្ជីឈ្មោះសិស្សអាហារូបករណ៍រួម រួចបញ្ជូនទៅតាមសាលារៀនវិញដើម្បីប្រកាសព័ត៌មានសម្រាប់រាជធានី ខេត្តរបស់ខ្លួន និងសម្រាប់រៀបចំសំណុំឯកសារស្នើសុំថវិកា និងបញ្ជូនមកក្រុមការងារអាហារូបករណ៍នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
- ប្រមូល និងចងក្រងទិន្នន័យរបស់សាលារៀនគោលដៅទៅក្នុងប្រព័ន្ធទិន្នន័យ

- រៀបចំផែនការអនុវត្តការផ្តល់អាហារូបករណ៍ដល់សិស្សគោលដៅរៀងរាល់ឆ្នាំ
- រៀបចំសំណុំឯកសារសំណើសុំថវិកាប្រតិបត្តិ និងថវិកាអាហារូបករណ៍ រួចបញ្ជូនមកក្រុមការងារអាហារូបករណ៍នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅដោយភ្ជាប់ជាមួយនូវបញ្ជីឈ្មោះសិស្សអាហារូបករណ៍ផ្លូវការដែលបានអនុម័តរួច
- រៀបចំឯកសារជូនដំណឹង កំណត់ពេលវេលា និងសម្របសម្រួលការបើកប្រាក់អាហារូបករណ៍
- ធ្វើរបាយការណ៍រីកចម្រើនបវេសនកាល ប្រចាំឆមាស និងប្រចាំឆ្នាំ រួចផ្ញើទៅក្រុមការងារអាហារូបករណ៍នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
- រៀបចំកិច្ចប្រជុំប្រចាំឆមាសដើម្បីពិនិត្យលើរបាយការណ៍ឆមាស និងដោះស្រាយបញ្ហាផ្សេងៗដែលកើតមានទាក់ទងនឹងការផ្តល់អាហារូបករណ៍ដល់សិស្ស
- ចុះធ្វើអធិការកិច្ច ពិនិត្យតាមដាន និងគាំទ្រគណៈកម្មការនៅថ្នាក់សាលារៀនរាល់ដំណាច់ឆ្នាំសិក្សានីមួយៗ និងនៅពេលដែលចាំបាច់
- បំពេញកិច្ចការផ្សេងទៀតក្នុងដំណើរការផ្តល់អាហារូបករណ៍ដល់សិស្សតាមការចំបាច់ ។

**ខ. គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់មូលដ្ឋាន(គ.គ.អ.ម/LSMC)**

១. សមាសភាព

| | |
|---|---|
| ១. នាយក នាយិកា | ប្រធាន |
| ២. ប្រធានគណៈកម្មការទ្រទ្រង់សាលារៀន | អនុប្រធាន |
| ៣. នាយករង ឬនាយិការងទទួលបន្ទុកមធ្យមសិក្សាទុតិយភូមិ | សមាជិក |
| ៤. លេខាធិការ ឬហេរញ្ញិក | សមាជិក |
| ៥. តំណាងគ្រូបង្រៀន (អាទិភាពនារី) | សមាជិក |
| ៦. តំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ទទួលបន្ទុកកិច្ចការនារី និងកុមារ | សមាជិក |

២ .ភារកិច្ច និងការងារទទួលខុសត្រូវ

- រៀបចំផែនការការងារផ្តល់អាហារូករណ៍ដល់សិស្សក្រីក្ររៀនពូកែ និងសិស្សពូកែមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា
- ផ្សព្វផ្សាយព័ត៌មានអាហារូបករណ៍ឱ្យបានទូលំទូលាយដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍ ស្របតាមការណែនាំរបស់ក្រសួង និងគម្រោង
- ជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្ររៀនពូកែ និងសិស្សពូកែមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យាដោយធានាឱ្យមានតម្លាភាព និងអនុវត្តតាមនីតិវិធី និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស

- ដោះស្រាយរាល់បណ្ដឹងតវ៉ា និងបាតុភាពនានាទាក់ទងនឹងការជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្ររៀនពូកែ និងសិស្សពូកែមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា និងការផ្ដល់អាហារូបករណ៍ដល់សិស្ស
- រៀបចំកត់ត្រាចំណូលចំណាយក្នុងការផ្ដល់អាហារូបករណ៍ និងចុះហត្ថលេខាលើទម្រង់ឯកសារ ឬបង្កាន់ដៃសម្រាប់ប្រើប្រាស់ក្នុងការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្ររៀនពូកែ និងសិស្សពូកែមុខវិជ្ជាមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា
- រៀបចំសំណុំឯកសារសំណើសុំថវិកាប្រតិបត្តិ និងថវិការអាហារូបករណ៍ ទៅក្រុមការងារអាហារូបករណ៍របស់ក្រសួង តាមរយៈ គ.គ.អ.ខ តាមកាលបរិច្ឆេទដែលបានកំណត់
- ជូនដំណឹងដល់សិស្ស និងអ្នកអាណាព្យាបាលសិស្សយ៉ាងតិច ៤ថ្ងៃមុន តាមកាលបរិច្ឆេទ ទីកន្លែង ពេលវេលានៃការបើកប្រាក់អាហារូបករណ៍ និងណែនាំអំពីឯកសារពាក់ព័ន្ធដែលត្រូវយកមកជាមួយដូចជា អត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ កិច្ចសន្យា ហើយផ្ដាំផ្ញើដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សឱ្យជូនកូនមកទទួលប្រាក់អាហារូបករណ៍
- រៀបចំសំណុំឯកសារ និងបញ្ជីវត្តមានសិស្សអាហារូបករណ៍ និងបញ្ជាក់វត្តមានសរុបរបស់សិស្សគិតជាភាគរយមករៀនធៀបនឹងថ្ងៃសិក្សាសរុប (ភាគរយមករៀនស្មើនឹងចំនួនវត្តមានគុណនឹង ១០០ រួចចែកនឹងចំនួនថ្ងៃសិក្សា)
- ចូលរួមជួយសម្របសម្រួល និងធ្វើជាសាក្សីក្នុងសកម្មភាពបើកប្រាក់អាហារូបករណ៍
- តាមដានវត្តមាន និងការសិក្សារបស់សិស្សអាហារូបករណ៍ជាប្រចាំ និងធ្វើទំនាក់ទំនងទៅអ្នកអាណាព្យាបាលសិស្សចំពោះសិស្សទាំងឡាយណាដែលអវត្តមានច្រើន ឬអវត្តមានពី០២ (ពីរ) ទៅ០៣ (បី)ថ្ងៃជាប់ៗគ្នា
- រៀបចំកិច្ចប្រជុំ គ.គ.អ.ម ប្រចាំខែសម្រាប់ការផ្ដល់អាហារូបករណ៍ដល់សិស្សដើម្បីពិភាក្សាវាយតម្លៃពីការរីកចម្រើន និងបញ្ហានានាដូចជាបញ្ហាសិស្សអវត្តមាន និងធ្លាក់មធ្យមភាគជាដើម
- រៀបចំរបាយការណ៍រីកចម្រើន រួចផ្ញើទៅ គ.គ.អ.ខ តាមកាលបរិច្ឆេទដែលបានកំណត់ និងរក្សាទុកដាក់ឯកសារទាក់ទងនឹងការផ្ដល់អាហារូបករណ៍ដល់សិស្សឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព
- បំពេញកិច្ចការដទៃទៀតក្នុងដំណើរការផ្ដល់អាហារូបករណ៍ដល់សិស្សតាមការចាំបាច់
- ប្រធាន ឬអនុប្រធានគណៈកម្មការទ្រទ្រង់សាលារៀន មានភារកិច្ចបន្ថែម ជាអ្នកសម្របសម្រួលលើដំណើរការជ្រើសរើសក្រុមសិស្សអាហារូបករណ៍
- តំណាងក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ចបន្ថែម ជាទីប្រឹក្សានៃដំណើរការជ្រើសរើសក្រុមសិស្ស

អាហារូបករណ៍។

**គ. ការកំណត់វិទ្យាល័យគោលដៅ**

គ្រប់វិទ្យាល័យដែលមានអគារធនធាន និងស្ថិតក្នុងផែនការរបស់គម្រោងសម្រាប់សាងសង់អគារធនធានបន្ថែមនឹងត្រូវបានចាត់ទុកជាវិទ្យាល័យគោលដៅអាទិភាពសម្រាប់កម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ រៀនពូកែ និងសិស្សពូកែលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ។

វិទ្យាល័យគោលដៅ និងវិទ្យាល័យដែលជាបណ្តាញរបស់វិទ្យាល័យធនធានដែលស្ថិតនៅក្នុងខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ឧត្តរមានជ័យ ព្រះវិហារ កោះកុង និងខេត្តប៉ៃលិន នឹងទទួលបានអាទិភាពខ្ពស់ក្នុងការទទួលបានអាហារូបករណ៍សរុបចំនួន ៦០% ខណៈដែលរាជធានី ខេត្តផ្សេងទៀត នឹងទទួលបានចំនួន ៤០% ( តាមនិយាមកំណត់នៃការជ្រើសរើសសិស្សអាហារូបករណ៍៦០% ត្រូវផ្តល់ទៅឱ្យសិស្សស្រី និង ៤០% ទៀតត្រូវបានផ្តល់ទៅសិស្សប្រុស)។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរ អប់រំ យុវជន និងកីឡា រាជធានី ខេត្ត ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់វិទ្យាល័យគោលដៅក្រោមឱវាទ និងចាត់តាំងអនុវត្តឱ្យបានត្រឹមត្រូវចាប់ពីឆ្នាំសិក្សា២០១៧-២០១៨ រហូតដល់ចប់គម្រោង។ ៕

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អង្គភាពពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- ធនាគារអភិវឌ្ឍអាស៊ី

  " ដើម្បីជូនជ្រាប "
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- វិទ្យាល័យគោលដៅ

  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ-ឯកសារ នា.មចទ